## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាអាជ្ញាកណ្តាល**

មជ្ឈមណ្ឌលភ្នំពេញ, អាគារ (A) , វិថី

សុធារស, សង្កាត់ទន្លេបាសាក់, ខណ្ឌចំការមន

ទូរស័ព្ទ/ទូរសារ : (៨៥៥-២៣) ២២០ ៧៩៣

**លេខ និងឈ្មោះសំណុំរឿង : ៦១/០៥ — ម៉ាកាឡូត**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៥**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសឡើងដោយភាគីនិយោជក : **អ៊ុក រី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត : **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ : **រុន សារ៉ាយ**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ : ក្រុមហ៊ុន ម៉ាកាឡូត ហ្គាមិន (ខេមបូឌា)

អាសយដ្ឋាន : សួនឧស្សាហកម្មវ៉ឺឡុន: ផ្លូវវែងស្រេង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០២៣ ៨៨៥ ៧៤៦ ០១២ ៥២២ ២៦៦ ទូរសារលេខ : ០២៣ ៩៨៥ ៦៩២

**តំណាងភាគីនិយោជក :**

១- លោក ឡុង ហ៊ាង មន្ត្រី GMAC

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ : សហព័ន្ធសហជីពជាតិកម្មករកម្ពុជា និង សហជីពជាតិកម្មករកម្ពុជាប្រចាំក្រុមហ៊ុន ម៉ាកឡូត

អាសយដ្ឋាន : ផ្ទះលេខគ្មាន ផ្លូវលេខ ២៧១ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៩៦៦ ៨៩៧ ០១៦ ៣២៤ ៦២២ ទូរសារៈ គ្មាន

**តំណាងកម្មករនិយោជិត :**

១- លោក តុល ផាន់មឿង ប្រធានសហព័ន្ធសហជីពជាតិកម្មករកម្ពុជា

២- លោក លៀង សុភា អនុប្រធានសហព័ន្ធសហជីពជាតិកម្មករកម្ពុជា

៣- លោក ហ៊ូ សារឿន ប្រធានសហជីពជាតិកម្មករកម្ពុជាប្រចាំក្រុមហ៊ុន ម៉ាកាឡូត

៤- លោក ហ៊ីង ប៊ុនធឿន អនុប្រធានសហជីពជាតិកម្មករកម្ពុជាប្រចាំក្រុមហ៊ុន ម៉ាកាឡូត

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

យោងតាមកំណត់ហេតុក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា ចំណុចបញ្ហាមិនសះជាខាងក្រោម ជាការទាមទាររបស់ភាគីកម្មករនិយោជិតនៃសំណុំរឿងវិវាទៈ

១- ភាគីកម្មករនិយោជិតទាមទារអោយក្រុមហ៊ុនទទួលលោក ហ៊ូ សារឿន ប្រធានសហជីព លោក ហ៊ីង ប៊ុនធឿន អនុប្រធានសហជីព និងលោក កន សារុន ទីប្រឹក្សាសហជីព ឱ្យចូលធ្វើការវិញ ដោយបញ្ជាក់ថា ការព្យួរកិច្ចសន្យាការងារនេះ គឺជាការរើសអើងសហជីព។ ដោយឡែកភាគីនិយោជកបានបញ្ជាក់ថា ចំពោះថ្នាក់ដឹកនាំទាំងបីខាងលើ ក្រុមហ៊ុនសំរេចព្យួរកិច្ចសន្យាមួយរយៈសិន ដោយមូលហេតុថា កាលពី ថ្ងៃទី ១៥ ១៧ និងទី១៨ ខែតុលា ឆ្នាំ២០០៥ អ្នកទាំងបីបានរារាំងកម្មករនិយោជិតផ្នែកតុកាត់មិនឱ្យចូលធ្វើការ ។ ការព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុននឹងអនុវត្តតាមច្បាប់ក្រោយពីសមត្ថកិច្ចពាក់ព័ន្ធធ្វើការ ដោះស្រាយចប់សព្វគ្រប់ហើយ ។

២- ក្នុងរយៈពេលធ្វើកូដកម្ម ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ធ្វើការទៀងទាត់ឱ្យនៅដដែល ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា កម្មករនិយោជិតចូលធ្វើការថ្ងៃណា ក្រុមហ៊ុននឹងផ្តល់ប្រាក់ឈ្នួលនៅថ្ងៃនោះ ពោលគឺអនុវត្តតាមច្បាប់ស្តីពីការងារ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាល ទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) ជំពូកទី១២ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ០៩៩ និង ប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ៥១៣ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៥ (អាណត្តិទីបី)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូក ទី ១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ៥១៩ ក.ក.ប.វ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៥ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៥ ។

## សវនាការ និង សង្ខេបនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ “A” វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៥ (វេលាម៉ោង ១៤:០០ ដល់ម៉ោង ១៧:៣០ នាទី រសៀល)

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៥ នាយកដ្ឋានវិវាទការនៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈបានទទួលបណ្តឹងផ្ទាល់មាត់ពីកម្មករនិយោជិត ស្តីពីការធ្វើកូដកម្មទាមទារអោយក្រុមហ៊ុន ម៉ាកាឡូត កែលំអល័ក្ខខ័ណ្ឌការងារអោយបានត្រឹមត្រូវតាមច្បាប់ស្តីពីការងារ ។ មន្ត្រីវិវាទការងារប្រចាំខណ្ឌដង្កោបានធ្វើការផ្សះផ្សាវិវាទនេះដល់ទីតាំងរោងចក្រ និង បានធ្វើការផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៥ លើចំណុចទាមទារ ៤ ចំណុច ហើយបានទទួលលទ្ធផលសះជា០២ចំណុចរបស់កម្មករ រីឯ០២ចំណុចទៀតគឺមិនសះជា។ នៅថ្ងៃទី២០ ខែតុលា ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលសំណុំរឿង និងរបាយការណ៍ស្តីពីវិវាទការងារមិនសះជាលេខ ៥១៩ កកបវ/វក ពីនាយកដ្ឋានវិវាទការងារនៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ។

នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៥ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលពីបណ្តឹងពីក្រុមហ៊ុន ម៉ាកាឡូត ដើម្បីស្នើសុំអោយក្រុមប្រឹក្សាអាជ្ញាកណ្តាលជួយធ្វើអន្តរាគមន៍ និងសុំអោយកម្មករដែលបានធ្វើកូដកម្មចូលធ្វើការវិញ។

នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៥ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញបញ្ជាអោយកម្មករនិយោជិតទាំងអស់ដែលបានធ្វើកូដកម្មចូលធ្វើការវិញនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៥ តាមវេនការងាររបស់ខ្លួនរហូតដល់មានការចេញសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៥ នៅវេលាម៉ោង ១៤:០០ រសៀល ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការផ្សះផ្សា និង ធ្វើសវនាការលើករណីមិនសះជា០២ចំណុច ដែលនៅសល់។ នៅពេលធ្វើសវនាការ ភាគីទាំងពីរបានព្រមព្រៀងសះជានឹងគ្នានូវចំណុចទី២។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនធ្វើសេចក្តីសម្រេចលើចំណុចទី២នេះទៀតទេ ។

ភាគីនិយោជកបានផ្តល់ឯកសារមួយចំនួន តែស្នើសុំអោយក្រុមប្រឹក្សាអាជ្ញាកណ្តាល មិនត្រូវផ្តល់ឯកសារនោះជូនទៅភាគីកម្មករឡើយ ។ ហើយនៅក្នុងលិខិតនោះភាគីនិយោជកបានសុំកុំអោយសួរនាំសាក្សី ដែលមាននៅក្នុងរបាយការណ៍នោះនៅពេលសវនាការនូវចំពោះមុខភាគីម្ខាងទៀតដែរ ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនយកឯកសារទាំងនោះ មកធ្វើជាភស្តុតាងក្នុងការដោះស្រាយវិវាទនេះឡើយ ។

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន

**ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក : គ្មាន**

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត**

១- វិញ្ញាបនប័ត្រចុះបញ្ជិកាលេខ ៨០០ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៥ ។

២- លិខិតលេខ ០០៣ សសជកក/០៩.០៥ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៥ របស់សហព័ន្ធសហជីពជាតិកម្មករកម្ពុជា គោរពជូន នាយកក្រុមហ៊ុន ម៉ាកាឡូត ស្តីពីការសុំជួបពិភាក្សាការងារស្តីពីលក្ខខណ្ឌការងារទូទៅ និងសេរីភាពសហជីព ។

៣- លិខិតគ្មានលេខ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៥ របស់សហព័ន្ធសហជីពជាតិកម្មករកម្ពុជា គោរពជូន ប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ចោមចៅ ស្តីពីការប្តឹងនាយកក្រុមហ៊ុន ម៉ាកាឡូត ពីបទគំរាមកំហែងលើរូបរាងកាយ ។

៤- លិខិតគ្មានលេខ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៥ របស់សហជីពជាតិកម្មករកម្ពុជានៃរោងចក្រ ម៉ាកាឡូត គោរពចូលមក សហព័ន្ធសហជីពជាតិកម្មករកម្ពុជាស្តីពីការប្តឹងនាយកក្រុមហ៊ុន ម៉ាកាឡូត ពីបទគំរាមកំហែងលើរូបរាងកាយ និងជ្រៀតជ្រែកការងាររបស់សហជីព ។

៥- លិខិតគ្មានលេខ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៥ របស់សហព័ន្ធសហជីពជាតិកម្មករកម្ពុជា គោរពជូន នាយកអង្គការ ACILS ស្តីពីការជួយអន្តរាគមដល់ម្ចាស់ទីផ្សារ ។

៦- លិខិតណាត់ជួប ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៥ របស់សហព័ន្ធសហជីពជាតិកម្មករកម្ពុជា គោរពជូន នាយកក្រុមហ៊ុន ម៉ាកាឡូត ស្តីពីការសុំជួបពិភាក្សាការងារស្តីពីសណ្តាប់ធ្នាប់នៅក្នុងរោងចក្រ ការទទួលស្គាល់សេរីភាពសហជីព និងសិទ្ធិចរចារជាមូលដ្ឋាន ។

៧- កិច្ចសន្យាការងាររយៈពេល១ឆ្នាំ របស់ ហ៊ូ សារឿន និង ហ៊ីង ប៊ុនធឿន ។

៨- ញត្តិគាំទ្ររបស់កម្មករនិយោជិតមួយចំនួននៃរោងចក្រ ម៉ាកាឡូត ក្នុងការគាំទ្រថ្នាក់ដឹកនាំសហជីពទាំងបីរូប ឱ្យចូលធ្វើការនៅកន្លែងដើមវិញ ។

៩- លិខិតគ្មានលេខ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៥ របស់សហព័ន្ធសហជីពជាតិកម្មករកម្ពុជា គោរពជូន ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ស្តីពីការប្តឹងនាយកក្រុមហ៊ុន ម៉ាកាឡូត ពីបទបង្ករបួសស្នាម ដោយចេតនា និងរើសអើងសហជីព។

១០- លិខិតគ្មានលេខ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៥ របស់សហព័ន្ធសហជីពជាតិកម្មករកម្ពុជា គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ប្តឹងនាយកក្រុមហ៊ុន ម៉ាកាឡូត ពីបទមិនឱ្យកម្មករទាំងអស់ ចូលធ្វើការទៅតាមសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៥។

១១- លិខិតលេខ១៨៩/០៥ អ.ស.ព.ក. ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៥ របស់អង្គការសហព័ន្ធ ពលករកម្ពុជា គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំជួយដោះស្រាយវិវាទការងារដល់ កម្មករចំនួន ៣ រូប ដែលត្រូវបានក្រុមហ៊ុនបញ្ឈប់ពីការងារ ។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុនតាក់ហ្វាតលេខ ៥១៩ ក.ក.ប.វ/វ.ក របស់លោក កុយ ទេពដារ៉ារុធ ប្រធាននាយកដ្ឋានវិវាទការងារចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៥។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៥ ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- សេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០០៩ កបអ. ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៥។

## អង្គហេតុ

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :

- ក្រុមហ៊ុន ម៉ាកាឡូត ស្ថិតនៅសួនឧស្សាហកម្មវឌ្ឍនៈ ផ្លូវវែងស្រេង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ដែលមានជួលកម្មករសរុបចំនួន ១.២០០ នាក់ ។
- សហជីពជាតិកម្មករកម្ពុជាបានចុះបញ្ជិកានៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០០៥ ។

- លោក ហ៊ូ សារឿន  លោក ហ៊ីង ប៊ុនធឿន  និង  លោក កន សារុន ជាថ្នាក់ដឹកនាំសហជីព ដែលបានចុះបញ្ជិកានៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលលោក ហ៊ូ សារឿន ជាប្រធានសហជីព  លោក ហ៊ីង ប៊ុនធឿន ជាអនុប្រធានសហជីព និងលោក កន សារុន ជាទីប្រឹក្សាសហជីព ។
- នៅក្នុងសវនាការ និយោជកបានទទួលស្គាល់ថា ខ្លួនមិនបានជូនដំណឹង ឬសុំការអនុញ្ញាតពីអធិការការងារទេ មុននឹងបញ្ឈប់លោក ហ៊ូ សារឿន  លោក ហ៊ីង ប៊ុនធឿន  និង  លោក កន សារុន ។
- លោក ហ៊ូ សារឿន  លោក ហ៊ីង ប៊ុនធឿន  និង  លោក កន សារុន មិនធ្លាប់ទទួលការព្រមានជាលាយលក្ខណ៍អក្សរពីក្រុមហ៊ុនឡើយ ។
- នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៥ លោក ហ៊ូ សារឿន  លោក ហ៊ីង ប៊ុនធឿន  និង  លោក កន សារុន ត្រូវបានប្រធានក្រុមហ៊ុនប្តូរការងារផ្នែកមេកន្ត្រៃ(តុកាត់) ទៅផ្នែកបិតលេខវិញ។
- នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៥ អ្នកទាំងបីរូបខាងលើ ត្រូវបានប្រធានក្រុមហ៊ុនបញ្ឈប់ពីការងារ ដោយសំអាងថាអ្នកទាំងបីរូបពុំបានបំពេញការងារពេញលេញជូនក្រុមហ៊ុន និង ញុះញង់ឱ្យកម្មករមានភាពជ្រួលច្របល់ ដែលនាំឱ្យខាតបង់ផលប្រយោជន៍ដល់ក្រុមហ៊ុន និងកម្មករ ។ ភាគីកម្មករបានអះអាងថា ការបញ្ឈប់នេះមិនបានធ្វើតាមនីតិវិធី ហើយពួកគេមិនបានប្រព្រឹត្តិកំហុសឡើយ។
- នៅរសៀលថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៥ ខណៈដែលកំពុងធ្វើការ កម្មករផ្នែកតុកាត់ខ្លះបានធ្វើកូដកម្ម ដោយទាមទារអោយក្រុមហ៊ុនទទួលយកអ្នកទាំងបីរូបចូលធ្វើការវិញ។
- នៅថ្ងៃទី ១៩-២០ ខែតុលា ឆ្នាំ២០០៥  កម្មករទាំងអស់ក្នុងរោងចក្រ ម៉ាកាឡូត បានធ្វើកូដកម្ម។

## ហេតុផលនៃសេចក្តីសម្រេច

កម្មករទាំងបីរូបទាមទារអោយនិយោជកទទួលយកចូលធ្វើការវិញដោយអះអាងថា និយោជកបានបញ្ឈប់ពួកគេមិនស្របតាមនីតិវិធីច្បាប់ ហើយពួកគេបានអះអាងថា គេមិនបានប្រព្រឹត្តិកំហុសដូចការចោទប្រកាន់របស់និយោជកឡើយ ។ ចំណែកឯភាគីនិយោជកវិញបានអះអាងថា កម្មករទាំងបីរូបនេះបានប្រព្រឹត្តិនូវកំហុសធ្ងន់ដោយញុះញង់អោយកម្មករដ៏ទៃទៀតធ្វើកូដកម្ម ដែលធ្វើអោយក្រុមហ៊ុនខាតបង់ផលប្រយោជន៍ ។ នេះជាហេតុផលដែល ក្រុមហ៊ុនមិនទទួលយកអ្នកទាំងបីនេះអោយចូលធ្វើការវិញ ។

យោងតាមមាត្រា ២៩៣ នៃច្បាប់ការងារចែងថា *" រាល់ការបញ្ឈប់ប្រតិភូបុគ្គលិក ឬ រាល់ការបញ្ឈប់បេក្ខជនណាម្នាក់ពីការងាររបស់ខ្លួន អាចធ្វើទៅបានលុះត្រាតែមានការយល់ព្រមពីអធិការការងារ...........។*

យោងតាមប្រកាស ៣០៥ សកបយ. ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រង់ប្រការ ៤ ចែងថា : *ចាប់តាំងពីពេលដាក់ពាក្យសុំចុះបញ្ជីកាសហជីពកម្មករនិយោជិតទាំងអស់ដែលជាស្ថាបនិក ឬកម្មករនិយោជិត ដែលចូលជាសមាជិកសហជីពនេះ ក្នុងពេលកំពុងស្នើសុំចុះបញ្ជីកាត្រូវបានការការពារ ដូចគ្នានឹងប្រតិភូរបស់បុគ្គលិកដែរ..... និយោជកណាដែលបញ្ឈប់ ឬបណ្តេញកម្មករនិយោជិតពីការងារ ដែលបានទទួលការការពារ ស្របតាមបទបញ្ញាតិខាងលើ ដោយគ្មានការអនុញ្ញាតជាមុនពីអធិការការងារ ឬក៏ធ្វើអោយមានការខូចខាតណាមួយដល់កម្មករនិយោជិតនោះ ត្រូវទទួលពិន័យស្របតាមមាត្រា ៣៧៣ នៃច្បាប់ស្តីពីការងារ វិធានការទាំងឡាយរបស់និយោជក ដែលរំលោភបទបញ្ញាតិខាងលើនេះត្រូវចាត់ទុកជាមោឃៈ និងគ្មានតំលៃអ្វីទាំងអស់ ........ ។*

តាមរយៈការពិនិត្យមើលឯកសារ និងការធ្វើសវនាការចំពោះមុខភាគីទាំងពីរ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញថា ភាគីនិយោជកមិនបានអនុវត្តទៅតាមនីតិវិធីមុននឹងបញ្ឈប់ថ្នាក់ដឹកនាំសហជីពទាំងបីរូបនេះ ជាពិសេស គឺមិនបានសុំការអនុញ្ញាតពីអធិការការងារឡើយ ។ ទោះបីជាភាគីនិយោជកបានផ្តល់ឯកសារមួយចំនួនដើម្បីគាំទ្រអំណះអំណាងរបស់ខ្លួនក៏ដោយ តែភាគីតំណាងនិយោជកមិនអនុញ្ញាតអោយក្រុមប្រឹក្សាអាជ្ញាកណ្តាលប្រគល់ជូនទៅភាគីម្ខាងទៀត ឬសួរដេញដោលចំពោះមុខភាគីនោះឡើយ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចពិចារណាលើឯកសារទាំងនេះឡើយ (ប្រការ ២៧ នៃប្រកាសលេខ ០៩៩ សកបយ.) ។ ជាលទ្ធផលនិយោជកមិនបានផ្តល់ឯកសារ ឬសាក្សីអ្វីទាំងអស់ ដើម្បីបញ្ជាក់ថា អ្នកទាំងបីនេះបានប្រព្រឹត្តិកំហុសនោះដែរ ។

សរុបសេចក្តីមក ដោយសារតែ (១) ក្រុមហ៊ុនបានបញ្ឈប់អ្នកទាំងបីនេះ មិនស្របទៅតាមនីតិវិធីច្បាប់ហើយ (២)ខកខានមិនបានបង្ហាញភស្តុតាង ឬសាក្សីអ្វីទាំងអស់ដែលបញ្ជាក់ថា អ្នកទាំងបីនេះបានប្រព្រឹត្តិកំហុសធ្ងន់ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកត្រូវតែទទួលយកថ្នាក់ដឹកនាំ និង អ្នកដែលជាស្ថាបនិកសហជីពទាំងបីនាក់ ដែលមានឈ្មោះ ១. ឈ្មោះ ហ៊ូ សារឿន (ប្រធានសហជីព) ២. លោក ហ៊ីង ប៊ុនធឿន (អនុប្រធានសហជីព) និង ៣. លោក កន សារុន (ជាទីប្រឹក្សាសហជីព) អោយចូលធ្វើការវិញព្រមទាំងបើកប្រាក់រំលឹកគិតចាប់ពីថ្ងៃ ដែលក្រុមហ៊ុនបានព្យួរការងារអ្នកទាំងនោះ រហូតដល់ថ្ងៃដែលក្រុមហ៊ុនទទួលពួកគេចូលធ្វើការវិញ ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាល សំរេចចេញសេចក្តីបង្គាប់ដូចតទៅ :

**<u>បង្គាប់ និង សម្រេច</u>**

បង្គាប់អោយនិយោជកទទួលយក ១. ឈ្មោះ ហ៊ូ សារឿន (ប្រធានសហជីព) ២. លោក ហ៊ីង ប៊ុនធឿន (អនុប្រធានសហជីព) និង ៣. លោក កន សារុន (ជាទីប្រឹក្សាសហជីព) ចូលធ្វើការវិញ និងបើកប្រាក់រំលឹកគិតចាប់ពីថ្ងៃ ដែលនិយោជកព្យួរការងារអ្នកទាំងបីរូបខាងលើនេះ រហូតដល់ថ្ងៃដែលក្រុមហ៊ុនទទួលពួកគេចូលធ្វើការវិញ ។

ប្រភេទនៃសេចក្ដីបង្គាប់ : សេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច

*សេចក្ដីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្ដីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **អ៊ុក រី**

ហត្ថលេខា: -----------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **អន ណន**

ហត្ថលេខា: -----------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល :

ឈ្មោះ : **រ៉ុន សារ៉ាយ**

ហត្ថលេខា: -----------------------------